# របាយការណ៍ប្រចាំឆ្នាំ២០១៤ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

ផ្អែកតាមផែនការសកម្មភាពឆ្នាំ២០១៤ មន្ទីរបានយកចិត្តទុកដាក់ដឹកនាំ និងគ្រប់គ្រងលើគ្រប់វិស័យតាមរយៈការពង្រឹងវិន័យ ដើម្បីបង្កើនសមត្ថភាពមន្ត្រីគ្រប់ការិយាល័យទៅតាមរចនាសម្ព័ន្ធដែលមានស្រាប់ រួមចំណែកក្នុងការធ្វើឲ្យមន្ទីរមានដំណើរការល្អ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងឆ្នាំ២០១៤ កន្លងមកនេះ។ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន ដោយសម្រេចលទ្ធផលជាផ្លែផ្កាដូចខាងក្រោម÷

1. **ស្ថានភាពមន្ត្រីរាជការ**

ឆ្នាំ២០១៤ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ មានមន្ត្រីសរុបចំនួន ៣១ នាក់/ស្ត្រី ០៤ នាក់ ក្នុងនោះរួមមានថ្នាក់ដឹកនាំមន្ទីរ ចំនួន ២៩ នាក់/០០ (ប្រធានមន្ទីរ ០១ នាក់ និងអនុប្រធានមន្ទីរ ០២ នាក់)មន្ទីរអភិវឌ្ឍន៍ជនបទ មាន ១០ ការិយាល័យថ្នាក់ខេត្ត និងការិយាល័យថ្នាក់ស្រុកចំនួន ០២ ដែលមានមន្ត្រីប្រចាំការ ។

**ក. ការិយាល័យថ្នាក់ខេត្តៈ**

| | |
|---|---|
| ក.១. ការិយាល័យរដ្ឋបាលនិងបុគ្គលិក | មានមន្ត្រី ០៣ នាក់/០០ |
| ក.២. ការិយាល័យគណនេយ្យ និងហិរញ្ញកិច្ច | មានមន្ត្រី ០៣ នាក់/ស្ត្រី ០២ |
| ក.៣. ការិយាល័យផែនការ និងស្ថិតិ | មានមន្ត្រី ០៣នាក់/ស្ត្រី ០១ |
| ក.៤. ការិយាល័យផ្លូវជនបទ | មានបន្ត្រី០៣នាក់/ស្ត្រី ០០ |
| ក.៥. ការិយាល័យផ្គត់ផ្គង់ទឹកជនបទ | មានមន្ត្រី ០៣ នាក់/០០ |
| ក.៦. ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | មានមន្ត្រី ០២ នាក់/ ០០ |
| ក.៧. ការិយាល័យអភិវឌ្ឍន៍សហគមន៍ | មានមន្ត្រី០៣ នាក់/ស្ត្រី ០១ នាក់ |
| ក.៨. ការិយាល័យអភិវឌ្ឍន៍ជនជាតិភាគតិច | មានមន្ត្រី ០២ នាក់/០០ |
| ក.៩. ការិយាល័យបណ្តុះបណ្តាលនិងស្រាវជ្រាវ | មានមន្ត្រី ០២ នាក់/ ០០ |
| ក.១០. ការិយាល័យថែទាំសុខភាពជនបទ | មានមន្ត្រី ០២ នាក់/ ០០ |

**ខ. ការិយាល័យថ្នាក់ស្រុកៈ**

| | |
|---|---|
| ខ.១. ការិយាល័យស្រុកចិត្របុរី | មានមន្ត្រី ០១ នាក់/០០ |
| ខ.២. ការិយាល័យស្រុកឆ្លូង | មានមន្ត្រី ០១ នាក់/០០ ។ |

2. **សកម្មភាពថ្នាក់ដឹកនាំមន្ទីរ**

- ចូលរួមប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គណៈកម្មការរដ្ឋបាលនៅតំបន់វិនិច្ឆ័យឃុំស្នួល ថ្ងៃទី ០៤/ ០១/២០១៤ នៅសាលាខេត្តក្រចេះ

- ចូលរួមកិច្ចសម្ភាសន៍ពាក់ព័ន្ធ និងដំណើរការសវនកម្មយេនឌ័រក្នុង ផ.អ.៣ ថ្ងៃទី០៦/០១/២០១៤ នៅសាលប្រជុំ សាលាខេត្តក្រចេះ
- ចូលរួមប្រជុំផ្សព្វផ្សាយ និងដាក់ឲ្យប្រើប្រាស់ស្ថានីយ៍សហគមន៍ស្ត្រីដើម្បីទឹកស្អាត ឃុំសណ្ដាន់ ថ្ងៃទី ០៨/០១/២០១៤
- ចូលរួមប្រកាសតែងតាំងប្រធានរតនាគារខេត្តថ្មី នៅថ្ងៃទី១៣/០១/២០១៤
- ចូលរួមសម្ពោធអាគារអនុសាខាកាកបាទក្រហមស្រុកចិត្របុរី ថ្ងៃទី១៤/០១/២០១៤
- ចូលរួមទស្សនកិច្ចការងារអភិវឌ្ឍន៍តាមភូមិគោលដៅ របស់អង្គការ Action Aid ថ្ងៃទី១៤/០១/ ២០១៤
- ចូលរួមប្រជុំត្រួតពិនិត្យផែនការរៀបចំពិធីសម្ពោធភូមិកុមារ SOS ថ្ងៃទី១៤/០១/២០១៤ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមកិច្ចប្រជុំសាមញ្ញ អាណត្តិទី១ ឆ្នាំទី៥ បាន ចំនួន ០៥ លើក របស់ក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំអនុម័តប្រាក់កម្ចីសហគមន៍ សម្រាប់ធ្វើអាជីវកម្មនៅឃុំបុសលាវ ថ្ងៃទី១៦/០១/២០១៤
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយគម្រោងស្ដីពីភាពបន្សុំសន្តិសុខស្បៀងក្នុងសហគមន៍ ថ្ងៃទី១៦/០១/ ២០១៤ នៅសណ្ឋាគារ លី ជី
- ចូលរួមជាអធិបតីក្នុងអង្គសន្និបាទបូកសរុបការងាររបស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត ឆ្នាំ២០១២-២០១៣ និង ទិសដៅឆ្នាំ២០១៤ ថ្ងៃទី២៣-២៤/០១/២០១៤
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងបូកសរុបលទ្ធផលការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវលំជនបទ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំឆ្នាំ ២០១៣ នៅថ្ងៃទី២៨/០១/២០១៣ នៅរាជធានីភ្នំពេញ
- ចូលរួមប្រជុំបូកសរុបរបាយការណ៍ឆ្លើយតបតម្រូវការរបស់ស្ត្រី លើការងារអនាម័យទឹកស្អាត នៅថ្ងៃទី០៥/០២/២០១៣ នៅសាលប្រជុំ ផ.អ.៣ (សាលាខេត្តក្រចេះ)
- ចូលរួមវេទិកាសាធារណៈជួបជាមួយប្រជាពលរដ្ឋ ស្ដីពីការអនុវត្តគោលនយោបាយភូមិឃុំសុវត្ថិភាព នៅថ្ងៃទី១០/០២/២០១៣ នៅឃុំកំពង់ដំរី ស្រុកឆ្លូង និងនៅឃុំស្វាយជ្រះ ស្រុកស្នួលនៅថ្ងៃទី ១១/០២/២០១៣
- ចូលរួមបញ្ចុះខ័ណ្ឌសីមាវត្តសម្ដេចព្រះនាគសែន ហៅវត្តក្រពើនេនធន់ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ នៅថ្ងៃ ទី១២/០២/២០១៣
- ចូលរួមក្នុងកម្មវិធីអប់រំសីលធម៌ពុទ្ធសាសនាផ្សារភ្ជាប់ និងសង្គមដល់សិស្សវិទ្យាល័យព្រះមហាក្សត្រីកុសុមៈ នៅថ្ងៃទី១៣/០២/២០១៣ នៅវត្តប៉ាឆា

- ចូលរួមប្រជុំជាមួយគណៈកម្មការមហាផ្ទៃការពារជាតិ អង្កេតបោសសម្អាត និងមុខងារសាធារណៈ (ទី៨)នៃរដ្ឋសភា ដើម្បីស្វែងយល់ពីផលប៉ះពាល់បញ្ហាប្រឈម ក្នុងការអនុវត្តច្បាប់លិខិតបទដ្ឋានគតិយុត្តិនានា និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសកិច្ចការដែលពាក់ព័ន្ធនឹងសមត្ថកិច្ចទទួលខុសត្រូវរបស់គណៈកម្មការ នៅថ្ងៃទី១៨/ ០២/២០១៣ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមស្តាប់ការណែនាំរបស់ក្រុមការងារថ្នាក់ជាតិ ចុះជួយមូលដ្ឋាន ដើម្បីត្រួតពិនិត្យការអនុវត្តកម្មវិធីនយោបាយចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នៅព្រឹកថ្ងៃទី២៤/០២/២០១៣ នឹងពេលល្ងាចចូលរួម វេទិកាសាធារណៈជួបជាមួយប្រជាពលរដ្ឋ ស្តីពីការអនុវត្តគោលនយោបាយភូមិឃុំសុវត្ថិភាព នៅឃុំសំបុក ឃុំថ្មគ្រែ ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ចូលរួមកាត់ខ្សែបូសម្ពោធឧបដ្ឋានសាលា និងសមិទ្ធិផលនានាក្នុងវត្តបទុមមុនីវណ្ណារ៉ាម ភូមិរកាកណ្តាល សង្កាត់រកាកណ្តាល នៅថ្ងៃទី២៥/០២/២០១៣ ក្រោមអធិបតីភាព **ឯឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីកម្ម និងសំណង់
- ចូលរួមក្នុងពិធីសម្ពោធប្រពន្ធ័ចែកចាយទឹក និងស្រោចស្រពនៅភូមិកោះផ្តៅ ឃុំកំពង់ចាម ស្រុកសំបូរ នៅថ្ងៃទី២៥/០២/២០១៣
- ចូលរួមសិក្ខាសាលាស្តីពី ការបង្ហាញលទ្ធផលនៃការវិភាគប្រព័ន្ធក្សេត្របរិស្ថាន តំបន់ដីសម្បទានសង្គមកិច្ចឃុំសំបុក ឃុំចង្ក្រង់ នៅថ្ងៃទី២៨/០២/២០១៤ របស់មន្ទីរកសិកម្មខេត្ត
- ចូលរួមពិធីវេទិការយុវជនតំបន់ត្រីកោណ កម្ពុជា ឡាវ និងវៀតណាមលើកទី៥ របស់មន្ទីរអប់រំយុវជន
- ចូលរួមសម្ពោធពិព័ណ៌ពាណិជ្ជកម្ម តំបន់ត្រីកោណ កម្ពុជា ឡាវ និងវៀតណាម លើកទី២ នៅខេត្តក្រចេះ
- ចូលរួមចូលរួមពិធីប្រកាសអនុក្រឹត្យ របស់រាជរដ្ឋាភិបាល ស្តីពី ការទទួលស្គាល់សមាជិកសភាពាណិជ្ជកម្ម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តរតនគីរីនៅសណ្ឋាគារ ហ៊ារ ប៊ុន្នី ខេត្តក្រចេះ នៅថ្ងៃទី០២/០៣/២០១៤
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី១ ២០០៩-២០១៤ និងលើកទិសដៅ ឆ្នាំ២០១៤ របស់រដ្ឋបាលខេត្តក្រចេះ នៅថ្ងៃទី ០៥-០៦/០៣/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមអបអរសាទរខួបលើកទី១០៣ នៃទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ ២០១៤ នៅសាលមហោស្រពខេត្ត

- ចូលរួមកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល របស់សាលាខេត្ត
- ចូលរួមជាគណៈអធិបតីភាព ក្នុងអង្គសិក្ខាសាលាថ្នាក់ខេត្តរបស់សមាគមសិស្ស-និស្សិតខេត្តក្រចេះ ស្តីពី មេរៀន ជីវិតសម្រាប់យុវជនលើកទី៧ ក្រោមប្រធានបទ ការបង្កើតធនាគារខួរក្បាល
- ចូលរួមប្រកាសតែងតាំង ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តក្រចេះ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំសាមញ្ញលើកទី៥៨ អាណត្តិទី១ ឆ្នាំទី៥ របស់ក្រុមប្រឹក្សាខេត្តនៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមជាវាគ្មិន និងជាគណៈអធិបតី ក្នុងពិធីវេទិកាស្រ្តីក្នុងភាពជាអ្នកដឹកនាំ លើការងារទឹកស្អាត និងសុខភាព
- ចូលរួមប្រជុំផ្សព្វផ្សាយគម្រោងអភិវឌ្ឍន៍សហគមន៍ នៅទីតាំងដីសម្បទានសង្គមកិច្ច ឃុំសំបុក ឃុំចង្រ្កង់
- ចូលរួមសម្ពោធឧបដ្ឋានវត្តគីរីវ័នារ៉ាម ជ្ររក្រូច ថ្ងៃទី ២៤/០៣/២០១៤
- ចូលរួមសិក្ខាសាលាចែករំលែកព័ត៌មានពីបរិស្ថាន ដល់មន្រ្តីរាជការ នៃអង្គភាពមន្ទីរពាក់ព័ន្ធជុំវិញខេត្ត
- ចូលរួមប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពី ការប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីវិសោធន៍កម្ម ស្តីពីការប្រឆាំង អំពើពុក រលួយនៅថ្នាក់ស្រុក ក្រុង និងឃុំ ថ្ងៃទី ២៦/០៣/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមសន្និបាទបូកសរុបការងារ ឆ្នាំ២០១៣ របស់មន្ទីរសុខាភិបាល ថ្ងៃទី៧-៨/០៤/២០១៤
- ចូលរួមសំណេះសំណាលសួរសុខទុកអតីតយុទ្ធជនដែលទទួលបានផ្ទះ និងដីសម្បទាន នៅភូមិសំបូរ ឃុំស្វាយជ្រះ នៅថ្ងៃទី០៥/០៤/២០១៤
- ចូលរួមក្នុងពិធីប្រកាសសម្រួលភារកិច្ច និងតែងតាំង ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តក្រចេះ ថ្ងៃទី ០៨/០៤/២០១៤
- ចូលរួមប្រជុំឆ្លងផែនការសកម្មភាពត្រីមាសទី២ (មេសា-មិថុនា)របស់សាលាខេត្ត នៅថ្ងៃទី០៨/០៤/២០១៤
- ចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងព័ត៌មាន និងផ្តល់ព័ត៌មានជាមុននៃគ្រោះមហន្តរាយ នៅថ្ងៃទី២៤/០៤/២០១៤
- ចូលរួមប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីគំរូការចែករំលែកផលប្រយោជន៍ សម្រាប់ (រេដ) កម្ពុជា នៅថ្ងៃ ទី២៥/០៤/២០១៤

- ចូលរួមត្រួតពិនិត្យវាយតម្លៃប្រគល់-ទទួលបញ្ចប់សុពលភាព ការងារជួសជុលអណ្តូងចំនួន ៦៨ កន្លែង របស់អង្គ ភាពលទ្ធកម្មខេត្តក្រចេះជូនដល់មន្ទីរ ថ្ងៃទី២៥/០៤/២០១៤
- ចូលរួមប្រជុំ ស្តីពី ការត្រៀមរៀបចំប្រារព្ធពិធីមីទ្ទិញរំលឹកខួបលើកទី ១៥១ ទិវាពិភពលោក កាកក្រហម និងអឌ្ឍចន្ទក្រហម ០៨ ឧសភា ២០១៤ នៅថ្ងៃទី៣០/០៤/២០១៤ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមក្នុងពិធីប្រកាសផ្ទេរតំណែង ព្រះរាជាអមសាលាដំបូងខេត្ត នៅថ្ងៃទី០២/០៥/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមក្នុងពិធីសម្ពោធវិហារអាហ្សាគីរីន នៅឃុំព្រែកសាម៉ាន់នៅថ្ងៃទី០៤/០៥/២០១៤
- ចូលរួមបើកដំណើរការដេញថ្លៃប្រេងឥន្ធនៈ និងប្រេងរំអិលជូនមន្ទីរជុំវិញខេត្ត ឆ្នាំ២០១៤ នៅថ្ងៃទី០៧/០៥/២០១៤ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមសិក្ខាសាលាស្តីពី តួនាទីសំខាន់របស់សហគមន៍មូលដ្ឋាន ក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដើម្បីនិរន្តរភាពសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ នៅថ្ងៃទី០៩/០៥/២០១៤ នៅសណ្ឋាគារ ហ៊ារ ប៊ុន្នី
- ចូលរួមមីទ្ទិញអបអរសាទររំលឹកខួបទី១៥១ ទិវាពិភពលោក កាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ ២០១៤ ក្រោមប្រធានបទ “ខ្ញុំ និងកាកបាទក្រហម” នៅថ្ងៃទី១០/០៥/២០១៤ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
- ចូលរួមពិធីសូត្រមន្ត ចម្រើនព្រះជន្មព្រះមហាក្សត្រ **សម្តេចព្រះនរោត្តមសីហមុនី** នៅថ្ងៃទី១២/០៥/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមវេទិកាពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីភាពជាដៃគូ និងយន្តការ ក្នុងការអនុវត្តរបៀបវារៈនៃការអភិវឌ្ឍន៍ នៅកម្ពុជាក្រោយឆ្នាំ២០១៥ នៅសណ្ឋាគារលីជី នៅថ្ងៃទី២០/០៥/២០១៤
- ចូលរួមប្រជុំពេញអង្គដើម្បីអនុម័ត លើសេចក្តីព្រាងលក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគ តិចនៅឃុំស្រែជិះ និងឃុំរលួសមានជ័យ ស្រុកសំបូរ ថ្ងៃទី២២-២៣/០៥/២០១៤
- ចុះទៅពិនិត្យការសាងសងស្ពានបេតុងផ្លូវថ្នលទាន នៅឃុំកោះខ្ញែរ ស្រុកសំបូរ
- ចូលរួមវេទិកាជួបជាមួយប្រជាពលរដ្ឋរបស់ក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន បានចំនួន ១១លើក
- ចូលរួមលើកការអនុវត្តការងារឆ្ពោះទៅរកជ័យលាភីផ្ការំដួល ២ ឬ ៣ ទង សម្រាប់ក្រុងក្រចេះ ថ្ងៃទី២៥/០៦/២០១៤ នៅសាលាក្រុងក្រចេះ
- ចូលរួមប្រជុំបង្ហាញពីស្ថានភាពគម្រោង បែងចែកដីសម្បទានសង្គមកិច្ច ថ្ងៃទី២៦/០៦/២០១៤ នៅសាលប្រជុំ ផ.អ.៣

- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ លើការរៀបចំលំហាត់សមយុទ្ធ ទៅលើប្រព័ន្ធផ្តល់ព័ត៌មានព្រមានជាមុន ថ្ងៃទី ៣០/០៦/២០១៤ នៅសាលាខេត្តក្រចេះ
- ចូលរួមក្នុងពិធីបុណ្យរុក្ខទិវា ឆ្នាំ២០១៤ នៅវិមានរណសិរ្ស២ធ្នូ ស្រុកស្នួលថ្ងៃទី ០៧/០៧/២០១៤
- ចូលរួមវាយតម្លៃប្រគល់បញ្ចប់សុពលភាពការងារជួលជុលផ្លូវជនបទ ក្រាលដីក្រួសចំនួន ០២ ខ្សែ ភូមិកែងប្រាសាទ ស្រុកសំបូរ និងភូមិបឹងលាច ស្រុកព្រែកប្រសព្វ នៅថ្ងៃទី ១០/០៧/២០១៤
- ចូលរួមចរចាថ្លៃការងារថែទាំផ្លូវជាលក្ខណៈប្រចាំចំនួន ២៤ គម្រោងអនុវត្តន៍ដោយប្រើប្រាស់ថវិកាជំពូក៦១ និងប្រជុំកាងារបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ ថ្ងៃទី១០/០៧/២០១៤ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមអង្គសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយការប្រើប្រាស់មួកសុវត្ថិភាព និងផលប៉ះពាល់នៃការបើកបរនៅពេលស្រវឹង ថ្ងៃទី ១២/០៧/២០១៤ នៅសណ្ឋាគារ លី ជី
- ចូលរួមប្រគេនទៀនព្រះវស្សា ចំនួន ១២ វត្ត ក្រុងក្រចេះ ថ្ងៃទី ១៣/០៧/២០១៤
- ចូលរួមកំណត់អត្តសញ្ញាណកម្ម និងបែងចែកដី សម្រាប់អភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជំហាន២ នៅឃុំថ្មី ស្រុកចិត្របុរី ឃុំចំបក់ ស្រុកព្រែកប្រសព្វ ថ្ងៃទី ១៥-១៦/០៧/២០១៤
- ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល ការងារបណ្តាញសហគមន៍ព្រៃឈើខេត្តក្រចេះ ថ្ងៃទី១៧/០៧/ ២០១៤ សណ្ឋាគារ ហ៊ា ប៊ុន្នី
- ចូលរួមប្រជុំសាមញ្ញ អាណត្តិទី២ ឆ្នាំទី១ បាន ០៥ លើក របស់ក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំការងារសាងសង់ និងជួសជុលអណ្តូងជីកប្រឡាយ និងស្តារស្រះចំនួន ២៣ គម្រោង ថ្ងៃទី១៨/០៧ /២០១៤ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមប្រជុំផ្សព្វផ្សាយ លិខិតក្រសួងមហាផ្ទៃលេខ០៤៥៩ សជណ ដើម្បីទប់ស្កាត់ការញុះញុងបង្កឲ្យមានអំពើ ហឹង្សាថ្ងៃទី ២១/០៧/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំពិភាក្សា កម្រិតជំនាញលើគម្រោងផែនការចំណូល-ចំណាយថវិកា ឆ្នាំ២០១៥ ថ្ងៃទី ២១/០៧/២០១៤ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមប្រជុំត្រៀមរៀបចំទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក ថ្ងៃទី២៩/០៧/២០១៤ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមក្នុងពិធីសម្ពោធអគារសិក្សា ០១ ខ្នង នៅឃុំកញ្ជរ ស្រុកឆ្លូង ថ្ងៃទី៣១/០៧/២០១៤
- ចូលរួមប្រជុំត្រៀមបង្ការហានិភ័យគ្រោះមហន្តរាយទឹកជំនន់ ថ្ងៃទី០៤/០៨/២០១៤ នៅសាលប្រជុំសាលាខេត្ត

- ចូលរួមចាក់វ៉ាក់សាំងការពារជំងឺសត្វពាហនៈ ថ្ងៃទី០៤/០៨/២០១៤ នៅទួលសុវត្ថិភាព (តាឃិន) ភូមិល្វាទង ឃុំបុសលាវ ស្រុកចិត្របុរី ក្រោមអធិបតីភាព **ឯកឧត្តម សរ ចំរុង** អភិបាលនៃគណៈអភិបាលខេត្តក្រចេះ
- ចូលរួមបូកសរុបលទ្ធផលការងារលើគ្រប់វិស័យ ឆ្នាំ២០១៤ បានចំនួន ១១ លើក នៅសាលប្រជុំសាលាខេត្ត
- ចូលរួមក្នុងពិធីប្រកាសចូលកាន់តំណែង ប្រធានមន្ទីរមុខងារសាធារណៈខេត្តក្រចេះ នៅថ្ងៃទី១២/០៨/២០១៤ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចាត់ក្រុមការងារចុះមូលដ្ឋានចូលរួមចែកអំណោយដល់ប្រជាពលរដ្ឋរងការលិចទឹកៈ
  - ថ្ងៃទី១២/០៨/២០១៤ នៅសាលាស្រុកឆ្លូង
  - ថ្ងៃទី១៣/០៨/២០១៤ នៅវត្តព្រែកប្រសព្វលើ ស្រុកព្រែកប្រសព្វ
  - ថ្ងៃទី១៤/០៨/២០១៤ នៅវត្តសណ្តាន់ ស្រុកសំបូរ
  - ថ្ងៃទី១៥/០៨/២០១៤ នៅវត្តអូរឬស្សីក្រុងក្រចេះ និងស្នាក់ការគណៈបក្ស ឃុំបុសលាវ
- ចូលរួមពីធីប្រកាសបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ ភូមិអូរឬស្សី១ និង២ សង្កាត់អូរឬស្សីក្រុង ក្រចេះ ថ្ងៃទី១៣/០៨/២០១៤ នៅវត្តអូរឬស្សី
- ចូលរួមក្នុងពិធីសំណេះសំណាល ផ្សព្វផ្សាយលទ្ធផល ការអនុវត្តការងារសម្បទានដីសង្គមកិច្ចសម្រាប់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ក្រោមអធិបតីភាព **ឯកឧត្តម ទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម** ថ្ងៃទី១៣/០៨/២០១៤ នៅសាលារៀនភូមិសំបូរមានជ័យ ឃុំស្វាយជ្រះ
- ចូលរួមចែកអំណោយកាកបាទក្រហមកម្ពុជាខេត្តក្រចេះ ជូនដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ថ្ងៃទី ១៣/០៨/២០១៤ នៅឃុំបុសលាវ ស្រុកចិត្របុរី
- ចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាមប្រព័ន្ធ Video Conference ០២ លើកនៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សាសិក្សាគម្រោង តាមស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តរួមគ្នា នៅទីតាំងដីសម្បទានសង្គមកិច្ច សម្រាប់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ថ្ងៃទី១៩/០៨/២០១៤ នៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត
- ចូលរួមផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការប្រើប្រាស់ធនធានមនុស្ស និងផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ថ្ងៃទី០៧/០៨/២០១៤ នៅសាលមហោស្រពខេត្តក្រចេះ
- ចូលរួមប្រជុំការបើកទូលាយ ដើម្បីត្រួតពិនិត្យវាយតម្លៃ សកម្មភាពការងារគ្រប់ផ្នែក រយៈពេលមួយឆ្នាំ របស់រដ្ឋបាលសាលាខេត្តក្រចេះ ថ្ងៃទី២៩/០៨/២០១៤

- ចូលរួមសម្ពោធអាគារសិក្សា ០១ ខ្នង ស្មើ ០៣ បន្ទប់ ជាអំណោយរបស់ក្រុមហ៊ុន HRI និង ប្រជាពលរដ្ឋជប៉ុន នៅភូមិល្អក់ ឃុំថ្មអណ្តើក ស្រុកចិត្របុរី ថ្ងៃទី០៣/០៩/២០១៤
- ចូលរួមចែកប័ណ្ណកម្មសិទ្ធដីធ្លី ជូនប្រជាពលរដ្ឋ ឃុំស្នួល នៅមហោស្រពខេត្តក្រចេះ ថ្ងៃទី០៣/០៩/ ២០១៤ ក្រោមអធិបតីភាព **ឯកឧត្តម ទេសរដ្ឋមន្រ្តី អ៊ឹម ឈុនលឹម**
- ចូលរួមពិភាក្សាពិគ្រោះយោបល់ ស្តីពី ការចងក្រងផែនការគ្រប់គ្រងព្រៃឈើ ថ្ងៃទី០៥/០៩/២០១៤ នៅសណ្ឋាគារ ហ៊ារ ប៊ុន្នី របស់ខ័ណ្ឌរដ្ឋបាលព្រៃឈើ
- ចូលរួមរៀបចំឯកសារក្រោយប្រជុំតំបន់ត្រីកោណ (CLV) នៅថ្ងៃទី០៣/០៩/២០១៤ នៅសាល ប្រជុំសាលាខេត្ត
- ចូលរួមប្រកាសផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងស្នងការ នៃស្នងការនគបាលខេត្តក្រចេះ ថ្ងៃទី០៨/០៩/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមកាន់បិណ្ឌនៅវត្តប៉ាឆា និងវត្តកសាងជាមួយ **ឯកឧត្តមអភិបាល** ខេត្តក្រចេះ ថ្ងៃទី០៨ និង ថ្ងៃទី១៤/០៩/២០១៤
- ចូលរួមប្រជុំណែនាំ ស្តីពីការរៀបចំតារាងវិភាគស្ថានភាពខេត្ត ក្នុងកិច្ចដំណើរការ កសាងផែនការ អភិវឌ្ឍន៍៥ឆ្នាំ របស់ខេត្ត ថ្ងៃទី១៧/០៩/២០១៤ នៅសាលប្រជុំរបស់សាលាខេត្តក្រចេះ
- ចូលរួមប្រជុំពិភាក្សាអំពីការសុំអនុញ្ញាត តបណ្តាញទឹកទំនើបកម្មប្រើដោយថាមពលពន្លឺព្រះអាទិត្យ នៅថ្ងៃទី ២៥/០៩/២០១៤ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមកិច្ចប្រជុំប្រមូលព័ត៌មានទិន្នន័យ សម្រាប់ចងក្រង GDP សាកល្បង របស់ខេត្តក្រចេះ ថ្ងៃទី២៩/០៩/២០១៤ នៅសណ្ឋាគារ ហ៊ារ ប៊ុន្នី
- ចូលរួមប្រជុំការងារវាយតម្លៃទីក្រុងស្អាតខេត្តក្រចេះ ថ្ងៃទី០៦/១០/២០១៤ នៅសាលាប្រជុំសាលា ខេត្ត
- ចូលរួមក្នុងទិវាមនុស្សចាស់កម្ពុជា ទិវាមនុស្សចាស់អន្តរជាតិ ១ តុលា ឆ្នាំ២០១៤ នៅថ្ងៃទី ០៧/១០/២០១៤ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សា និងពិនិត្យលើទិន្នន័យដីសហគមន៍ជនជាតិដើមភាគតិច ដែលវាស់វែងរួច នៅ ភូមិពន្ធដារ និងភូមិអូរកក់ ឃុំអូរគ្រៀង ថ្ងៃទី០៨/១០/២០១៤
- ចូលរួមប្រជុំបូកសរុប លទ្ធផលការងារលើគ្រប់វិស័យ ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៤ របស់ គណៈកម្មការនាយក មូលនិធិសមធមិខេត្តក្រចេះ ថ្ងៃទី០៩/១០/២០១៤ នៅមន្ទីរពេទ្យបង្អែកឆ្លូង និងថ្ងៃទី១០/១០/២០១៤ នៅមន្ទីរពេទ្យបង្អែកខេត្ត
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យ ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៤ ថ្ងៃទី១០/១០/ ២០១៤ នៅសាលប្រជុំសាលាខេត្ត

- ចូលរួមប្រជុំប្រចាំសប្តាហ៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី១៣/១០/២០១៤
- ចូលរួមប្រជុំត្រៀមរៀបចំពិធីគោរពវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនៈកោដ្ឋ** សម្រាប់ខួប ២ឆ្នាំ និងព្រះរាជពិធីបុណ្យអុំទូកអកអំបុកសំពះព្រះខែ ឆ្នាំ២០១៤ នៅថ្ងៃទី០៨/១០/២០១៤ នៅសាលប្រជុំសាលាខេត្ត និងគោរពព្រះវិញ្ញាណក្ខន្ធ ថ្ងៃទី ១៤/១០/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមសម្ពោធ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តក្រចេះ ថ្ងៃទី១៤/១០/ ២០១៤ នៅមជ្ឈមណ្ឌល អូរឫស្សី ២ សង្កាត់អូរឫស្សី
- ចូលរួមចែកអំណោយ ដល់ប្រជាពលរដ្ឋរងគ្រោះ ដោយសារទឹកជំនន់ទន្លេ ថ្ងៃទី១៥/១០/២០១៤ នៅស្រុកឆ្លូង
- ចូលរួមប្រគល់សញ្ញាបត្រដល់និស្សិតសិស្ស UME ថ្ងៃទី១៧/១០/២០១៤ នៅមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត
- ចូលរួមប្រជុំសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ ថ្ងៃទី២០/១០/ ២០១៤ នៅសាលប្រជុំរបស់ក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំបណ្តាញយេនឌ័រថ្នាក់ខេត្តថ្ងៃទី២១/១០/២០១៤ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តក្រចេះ
- ចូលរួមប្រជុំពិភាក្សា លើការងារធ្វើសមាហរណកម្មក្របខ័ណ្ឌមន្ត្រីរាជការ ការបញ្ចូលកាំប្រាក់ បៀវត្សមន្ត្រីរាជការ និងបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ នៅថ្ងៃទី២១/១០/២០១៤ និងប្រជុំ ពិនិត្យពិភាក្សាសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគមន៍ នៅថ្ងៃទី ២៤/១០/២០១៤ នៅ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមក្នុងពិធីសំណេះសំណាល ស្តីពីការចុះពិនិត្យមើលលទ្ធផលនៃការបោសសម្អាតមីនប្រចាំឆ្នាំ ២០១៤ នៅថ្ងៃ ទី៣១/១០/២០១៤ ភូមិច្រវ៉ា ឃុំកន្ទួត ស្រុកចិត្របុរី
- ចូលរួមក្នុងពិធីបើកបវេសនកាលឆ្នាំ ២០១៤-២០១៥ នៅថ្ងៃទី០៤/១១/២០១៤ នៅវិទ្យាល័យ ព្រះមហាក្សត្រីយានីកុសុមៈ
- ចូលរួមពិធីបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិន្ទ នៅថ្ងៃទី ១២/១១/២០១៤ នៅ សាលមហោស្រពខេត្ត
- ចូលរួមវេទិកាសាធារណៈជួបជាមួយប្រជាពលរដ្ឋ នៅភូមិថ្មី ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ថ្ងៃទី ១៩/១១/២០១៤ ។

3. **<u>សកម្មភាពតាមការិយាល័យ</u>** ៖

3.1. **<u>ការងារការិយាល័យរដ្ឋបាល និងបុគ្គលិក</u>**

- រៀបចំឯកសារបញ្ជីវត្តមានមន្ត្រីរាជការប្រចាំថ្ងៃ

- ទទួលលិខិតចូល ៧៥៤ ច្បាប់ របស់រាជរដ្ឋាភិបាល ក្រសួងសាមី អន្តរក្រសួង ក្នុងខេត្តទូទៅ
- លិខិតចេញ ៣៩០ ច្បាប់ ក្រសួងសាមី ផ្សេងៗទូទាំងខេត្ត
- លិខិតបេសកកម្ម ២៩១ លេខ
- សំណើមន្ត្រីសុំតាំងស៊ប់ ០៣ នាក់/០២ នាក់
- ទទួលក្របខ័ណ្ឌមន្ត្រីថ្មីចំនួន ០២ រូប/០០
- ធ្វើលិខិតអញ្ជើញមន្ត្រីឲ្យមកបម្រើការងារចំនួន ០២ រូប
- សំណើសុំគ្រឿងឥស្សរយសឆ្នាំ២០១៤ ចំនួន ០៩ រូប ស្ត្រី ០១ រូប
- សំណើសុំធ្វើនិយ័តកម្មថ្នាក់ឋានន្តរសិក្តដែលខកខានការតម្លើងថ្នាក់ស្របតាមវេនអតីតភាព ០១ រូប
- មន្ត្រីចូលនិវត្តន៍ ០១ រូប
- បានធ្វើកំណែប្រាក់បៀវត្ស និងបំណាច់មុខងារជូនមន្ត្រីចំនួន ១៣ រូប
- បានធ្វើសំណើសុំគោលការណ៍ឯកភាព លើសមាសភាពមន្ត្រីគ្រោងតែងតាំង ជាអនុប្រធានមន្ទីរ ០១ រូប ប្រធានការិយាល័យ ០៣ រូប និងអនុប្រធានការិយាល័យ ០៥
- រៀបចំសំណើសុំចូលនិវត្តន៍មន្ត្រី ០២ រូប/០១ ។

3.2. **<u>ការងារផ្លូវជនបទ</u>**

ផ្លូវថ្នល់គឺជាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដ៏សំខាន់ មានគោលដៅបម្រើឲ្យការដឹកជញ្ជូន ការទំនាក់ទំនងគ្នាពីតំបន់មួយទៅតំបន់មួយ ជាពិសេសជំរុញឲ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ ផ្លូវជនបទប្រៀបបានដូចសរសៃឈាម ដែលតភ្ជាប់ពីតំបន់ដាច់ស្រយាលមកទីប្រជុំជន។ ដោយផ្អែកលើផែនការសកម្មភាពប្រចាំឆ្នាំ ២០១៤ ការិយាល័យផ្លូវលំជនបទ អនុវត្តផែនការសម្រេចបានដូចខាងក្រោម÷

- ការងារថែទាំជាលក្ខណៈខួប មានចំនួន ០៥ ខ្សែ សរុបប្រវែង ៣៥.៨០ គ.ម
- ការងារថែទាំជាលក្ខណៈប្រចាំ មានចំនួន ០៧ ខ្សែ សរុបប្រវែង ៤៩.៥០ គ.ម
- ការងារជួសជុលចំនួន ០១ ខ្សែ មានប្រវែងសរុបចំនួន ១៩.២០ ម៉ែត្រ
- ការងារជួសជុលបន្ទាន់ចំនួន ០៣ ខ្សែមានប្រវែងសរុបចំនួន ៤.៥០ គ.ម
- ការងារដាក់លូទោល និងលូភ្លោះ មាន ៤ កន្លែង
- រៀបចំធ្វើសារពើភ័ណ្ឌផ្លូវបានចំនួន ២០៦ ខ្សែ ប្រវែង ១៩២៣.២៦២ម៉ែត្រ ។

3.3. **<u>ការងារផ្គត់ផ្គង់ទឹកជនបទ</u>**

ឆ្លងតាមការអនុវត្តលើវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ បានបង្ហាញឲ្យឃើញថា ទឹកស្អាត គឺមានសារៈប្រយោជន៍ដល់សុខភាពជួយសន្សំសំចៃពេលវេលា ព្រមទាំងបង្កើនឱកាសប្រកបមុខរបរចិញ្ចឹមជីវិតផងដែរ។ ដូច្នេះ នៅឆ្នាំ២០១៤ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានសាងសង់ និងជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមួយចំនួនដូចខាងក្រោម÷

- សាងសង់អណ្តូងស្នប់ថ្មី ១០ អណ្តូង ជួសជុលអណ្តូងស្នប់ ១៤៨ អណ្តូង និងអណ្តូងលូ ៣០ អណ្តូង
- ចុះចែកសម្ភារគ្រោះទឹកជំនន់ដល់ប្រជាពលរដ្ឋនៅតំបន់គោលដៅទាំង ៣ស្រុក ៥ ឃុំ ស្មើ ២៥ភូមិ មានធុងចម្រោះ ចំនួន ១៥០ ធុង សាប៊ូ LUX ចំនួន ៣៣៦៨ ដុំ កាន់ដាក់ទឹកចំណុះ ២០ លីត្រ ចំនួន ១៥២០ កាន ធុងទឹកចំណុះ ២០ លីត្រ ចំនួន ១០០០ ធុង សាប៊ូដុំចំនួន ១.៥២០ ដុំ ថ្នាំ Acpuatabs (អាក្វាថេប) ចំនួន ១០៤០០០ បន្ទះ ថ្នាំ Water Maker (ភ័រ) ចំនួណ ៤៦០០០ កញ្ចប់ និងខិតប័ណ្ណ រូបភាពចំនួន ៦០៨០ សន្លឹក ។

## 3.4. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

មន្ទីរមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងគោលបំណងលើកស្ទួយជីវភាព សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ ក្នុងសហគមន៍ ពិសេសលើកកម្ពស់សមត្ថភាពស្ត្រី។ ក្នុងឆ្នាំ២០១៣ មន្ត្រីមន្ទីរបានចូលរួមសហការចុះពង្រឹងក្រុមសន្សំប្រាក់បាន ០៤ ឃុំ ស្រុកសំបូរ ស្រុកចិត្របុរី និង ស្រុកព្រែកប្រសព្វ មានដូចខាងក្រោម ÷

- ចូលរួមប្រជុំពង្រឹងសហគមន៍ឃុំព្រែកប្រសព្វ ឃុំវឌ្ឍនៈ ស្តីពីការធ្វើផែនការសកម្មភាព និងថវិកា ការរៀបចំឯកសារដើម្បីចុះបញ្ជីឈ្មោះសហគមន៍ពេញសិទ្ធជាផ្លូវការ នៅក្រសួងមហាផ្ទៃ សរុបចំនួន ៤៥ នាក់ ស្ត្រី ៣១ នាក់
- ចូលរួមវគ្គបណ្តុះបណ្តាល ឃុំព្រែកប្រសព្វ ឃុំវឌ្ឍនៈ ស្តីពីការធ្វើផែនការអាជីវកម្មខ្នាតតូច របស់សហគមន៍ សរុបចំនួន ៦៩ នាក់ ស្ត្រី ៥៥ នាក់
- ចូលរួមប្រជុំក្រុមការងារអង្កេតព័ត៌មានសេដ្ឋកិច្ច និងសង្គមនៅការិយាល័យអង្គការ Oxfam ដែលសមាសភាពចូលរួមមានអង្គការ Kafdoc, Oxfam, PYD មន្ទីរកិច្ចការនារី មន្ទីរកសិកម្មខេត្ត សហគមន៍សន្សំប្រាក់ឃុំវឌ្ឍនៈ ឃុំព្រែកប្រសព្វ ឃុំកោះច្រែង និងឃុំបុសលាវ មានអ្នកចូលរួមចំនួន ១៥ នាក់ ស្ត្រី ៥ នាក់
- ចូលរួមប្រជុំ នៅឃុំព្រែកប្រសព្វ ផ្តល់កម្ចីដល់ប្រជាពលរដ្ឋមាន ចំនួន ២២ នាក់ ស្រី ៧ នាក់ ២៤,៦០០,០០០ រៀល និងឃុំកោះច្រែង ចំនួន ១៦ នាក់ ស្ត្រី ៦ នាក់ ៧៣,៣០០,០០០ រៀល
- ចូលរួមពិធីសម្ពោធមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តក្រចេះដាក់អោយប្រើប្រាស់ជាផ្លូវការដែលមានទីតាំងស្ថិតនៅបណ្តោយផ្លូវជាតិលេខ៧ ក្នុងភូមិឬស្សី សង្កាត់អូរឬស្សី ក្រុងក្រចេះ ។

## 3.5. ការងារអភិវឌ្ឍន៍សហគមន៍

ដើម្បីលុបបំបាត់ភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងពង្រឹងជីវភាពរស់នៅឲ្យប្រសើរ ស្របទៅនឹងគោលនយោបាយ ដ៏សំខាន់របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ ឲ្យប្រសើរឡើង ពីមួយថ្ងៃទៅមួយថ្ងៃការិយាល័យ អភិវឌ្ឍន៍សហគមន៍បានអនុវត្តសកម្មភាពដូចខាងក្រោម÷

- ចូលរួមប្រជុំពង្រឹងសហគមន៍ឃុំព្រែកប្រសព្វ ឃុំវឌ្ឍនៈ ស្តីពីការធ្វើផែនការសកម្មភាព និងថវិកា ការរៀបចំឯកសារដើម្បីចុះបញ្ជីឈ្មោះសហគមន៍ពេញសិទ្ធជាផ្លូវការ នៅក្រសួងមហាផ្ទៃ សរុបចំនួន ៤៥ នាក់ ស្ត្រី ៣១ នាក់
- ចូលរួមវគ្គបណ្តុះបណ្តាល ឃុំព្រែកប្រសព្វ ឃុំវឌ្ឍនៈ ស្តីពីការធ្វើផែនការអាជីវកម្មខ្នាតតូចរបស់សហគមន៍ សរុបចំនួន ៦៩ នាក់ ស្ត្រី ៥៥ នាក់
- ចូលរួមប្រជុំក្រុមការងារអង្កេតព័ត៌មានសេដ្ឋកិច្ច និងសង្គម នៅការិយាល័យអង្គការ Oxfam ដែលសមាសភាពចូលរួមមានអង្គការ Kafdoc, Oxfam, PYD មន្ទីរកិច្ចការនារី មន្ទីរកសិកម្មខេត្តសហគមន៍សន្សំប្រាក់ឃុំវឌ្ឍនៈ ឃុំព្រែកប្រសព្វ ឃុំកោះច្រែង និងឃុំបុសលាវ មានអ្នកចូលរួមចំនួន ១៥ នាក់ ស្ត្រី ៥ នាក់
- ចូលរួមប្រជុំនៅឃុំព្រែកប្រសព្វ ផ្តល់កម្ចីដល់ប្រជាពលរដ្ឋមាន ចំនួន ២២ នាក់ ស្រី ៧ នាក់ ២៤,៦០០,០០០ រៀល និងឃុំកោះច្រែង ចំនួន ១៦ នាក់ ស្ត្រី ៦ នាក់ ៧៣,៣០០,០០០ រៀល ។
- ចូលរួមពិធីសម្ពោធមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តក្រចេះ ដាក់អោយប្រើប្រាស់ជាផ្លូវការដែលមានទីតាំងស្ថិតនៅបណ្តោយផ្លូវជាតិលេខ៧ ក្នុងភូមិឬស្សី សង្កាត់អូរឬស្សី ក្រុងក្រចេះ ។

### 3.6. <u>**ការងារជនជាតិដើមភាគតិច**</u>

- ចូលរួមបើកកិច្ចប្រជុំលើកទី១ ដើម្បីប្រមូលព័តមាន និងទិន្នន័យ សម្រាប់កសាងសៀវភៅផែនការត្រៀមបម្រុងគ្រោះមហន្តរាយថ្នាក់ឃុំ សហការជាមួយ (Oxfam, CED)
- ចូលរួមប្រជុំពេញអង្គឆ្លងលក្ខន្តិក មានអ្នកចូលរួមសរុប ២៣៩ នាក់ ស្ត្រី ៧៨ នាក់ ក្នុងនោះមាន ឃុំស្រែជិះ មានចំនួន ៧៨ នាក់ ស្ត្រី ២៥ នាក់ ឃុំរលួសមានជ័យ មាន ១៦១ នាក់ ស្ត្រី ៥៣ នាក់
- ចុះស្រង់ទិន្នន័យស្ថិតិជនជាតិភាគតិច នៅក្នុងស្រុកសំបូរ ស្រុកចិត្របុរី ស្រុកស្នួល ខេត្តក្រចេះ
- សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច រៀបចំទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក លើកទី២០ ថ្ងៃទី០៩/ សីហា/ ២០១៤ នៅទីធ្លាមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត
- ចុះសហការជាមួយ និងមន្ទីរដែនដីនគរូបនីយកម្ម និងសំណង់ ខណ្ឌរដ្ឋបាលព្រៃឈើ អាជ្ញាធរឃុំអូរគ្រៀង និងសមាជិកសហគមន៍ជនជាតិដើម ភាគតិចព្នងភូមិអូរកក់ វាស់វាងដីសមូហភាព របស់សហគមន៍ជន ជាតិដើមភាគតិចព្នង នៅភូមិអូរកក់ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ
- ចូលរួមសម្របសម្រួលកិច្ចប្រជុំផ្សព្វផ្សាយ អំពីសារៈប្រយោជន៍នៃការរៀបចំសហគមន៍ជន ជាតិដើមភាគតិចនៅឃុំអូរគ្រៀងនិងឃុំបឹងចារដែលមានអ្នកចូលរួម២១៨នាក់ស្ត្រី១២៥នាក់
- ចូលរួមសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយពីការអនុវត្តយន្តការអន្តរក្រសួង លើការពង្រឹងការគ្រប់គ្រងសប្បទានដីសេដ្ឋកិច្ច នៅខេត្តរតនគីរី ។

## 3.7. ការងារថែទាំសុខភាពជនបទ

ការងារថែទាំសុខភាពជនបទ ជាកត្តាចាំបាច់ក្នុងការលើកស្ទួយសុខុមាលភាព របស់ប្រជាពលរដ្ឋ រួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។ ដើម្បីលើកកម្ពស់សហគមន៍ជនបទ ក្នុងទស្សន ការពារប្រសើរជាងព្យាបាល ការិយាល័យថែទាំសុខភាពជនបទ របស់មន្ទីរអភិវឌ្ឍន៍ខេត្តក្រចេះ បានសម្រេចភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួលបំផុសកម្មវិធី ក.ទ.អ.ស.ស ចលនាកន្លែងលាងសម្អាតដៃ នៅតាមសាលារៀន និងសហគមន៍ ឱ្យមានការផ្លាស់ប្តូរទម្លាប់មាន ០៣ សាលា ០៤ ភូមិ ក្នុងឃុំបុសលាវ ស្រុកចិត្របុរី មានអ្នកចូលរួម ៨៦ នាក់ ស្ត្រី ៥៦ នាក់
- យុទ្ធនាការផ្សព្វផ្សាយពីអនាម័យ ០២សាលា ០២ឃុំ ០២ស្រុក សិស្សចូលរួម ១៧១៥នាក់ ស្រី ៨៦៦នាក់
- ប្រជុំបំផុស និងផ្សព្វផ្សាយ ស្តីពីការសាងសង់បង្គន់បានចំនួន ២០ ឃុំ ០៤ ស្រុក អ្នកចូលរួម ២០២៦ នាក់ ៩៧៨ នាក់
- ផ្តល់សម្ភារសាងសង់បង្គន់ ចំនួន ១៥០ បង្គន់ នៅឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ និងឃុំវឌ្ឍនៈ ស្រុកសំបូរ
- ចុះផ្សព្វផ្សាយ និងបំផុសឱ្យប្រជាជនស្ម័គ្រចិត្តសាងសង់បង្គន់ដោយខ្លួនឯង ក្នុងភូមិគោលដៅមាន ១៥ ឃុំ ០៤ ស្រុក ១៥០១ បង្គន់
- បើកវគ្គបណ្តុះបណ្តាល ក.ទ.អ.ស ស្តីពីអនាម័យ និងទឹកស្អាត ដល់ក្រុមការងារនៅតាមសាលារៀន ក្នុងឃុំ ខ្សាច់អណ្តែតមានអ្នកចូលរួម ២៣ នាក់ ស្ត្រី ១២ នាក់
- កម្មវិធីទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា ឆ្នាំ២០១៤ ក្រោមប្រធានបទ វិនិយោគអនាម័យដើម្បី កូនចៅជំនន់ក្រោយ នៅសាលាបឋមសិក្សាភូមិក្រូច ឃុំដីវីផុង ស្រុកឆ្លូង មានអ្នកចូលរួមចំនួន ៣៦០ នាក់ ស្ត្រី ១៧២ នាក់ ។

## 3.8. ការងារបណ្តុះបណ្តាលមន្ត្រីរាជការ

- លោក លឹម ជាវហាវ ប្រធានមន្ទីរ លោក សន ធី ប្រធានការិយាល័យ លោក អ៊ុត អុល ប្រធានការិយាល័យ បានចូលរួមសិក្ខាសាលា ស្តីពីរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០១៥-២០១៧ និងដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពី ការតាមដានវាយតម្លៃថវិកាកម្មវិធីរបស់ ក.អ.ជ នៅថ្ងៃទី៦-៨/០៥/២០១៤ នៅរាជធានីភ្នំពេញ ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។
- លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ លោក ឈិត សុភា ប្រធានការិយាល័យ បានចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយផ្នែកយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ រយៈពេល ០៥ ឆ្នាំ (២០១៤-២០១៨) នៅថ្ងៃទី៣០ ខែមេសា ដល់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។

- លោក ឈិត សុភា ប្រធានការិយាល័យសេដ្ឋកិច្ចជនបទ បានចូលរួមសិក្ខាសាលា ស្តីពីអ្នកពាក់ព័ន្ធក្នុងខ្សែចង្វាក់ទីផ្សារបសុបក្សីខេត្តក្រចេះ កាលពីថ្ងៃទី ២៧/០៥/២០១៤ នៅខេត្តក្រចេះ ឧបត្ថម្ភដោយ CRDT។
- លោក លឹម ជាវហាវ លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ បានចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយនៃការការពាររបាយការណ៍ជាតិលើកទី ៤+៥ ស្តីពីការចុះអនុវត្តន៍អនុសញ្ញា CEDAW នៅទីក្រុងហ្សឺណែវ នៅថ្ងៃទី ០៥/០៦/២០១៤ នៅខេត្តក្រចេះ ឧបត្ថម្ភដោយក្រសួងកិច្ចការនារី។
- ធុន បូនិត (ស្រី) បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តន៍អនុសញ្ញា និងភាពជាអ្នកដឹកនាំសម្រាប់ថ្នាក់ដឹកនាំមន្ទីរនានាជុំវិញខេត្តចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៦/០៦/២០១៤ នៅខេត្តក្រចេះ ឧបត្ថម្ភដោយក្រសួងកិច្ចការនារី។
- លោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញគ្រប់គ្រងទិន្នន័យសកម្មភាពមីនស.ផ.ស ចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី ១៣/០៦/២០១៤ នៅខេត្តបាត់ដំបង ឧបត្ថម្ភដោយ CMAA។
- លោក ហៀង ហឿន អនុប្រធានការិយាល័យសេដ្ឋកិច្ចជនបទ បានចូលរួមសិក្ខាសាលា ស្តីពីដំណើរការបង្កើត និងចុះឈ្មោះសហគមន៍អភិវឌ្ឍន៍មូលដ្ឋាន ចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ២០/០៦/២០១៤ នៅស្រុកព្រែកប្រសព្វ និងស្រុកសំបូរ ឧបត្ថម្ភដោយ PYD។
- លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ និងលោក សោម ជួន អនុប្រធានការិយាល័យបណ្តុះបណ្តាល បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សរបស់ ក.អ.ជ កាលពីថ្ងៃទី២៤/០៧/២០១៤ នៅរាជធានីភ្នំពេញ ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។
- លោក លឹម ជាវហាវ លោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ លោក សន ធី ប្រធានការិយាល័យគណនេយ្យ និងប៊ូ វិច្ឆកា(ស្រី) មន្ត្រីការិយាល័យគណនេយ្យ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពអនុវត្តថវិកាកម្មវិធីរបស់ក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី២៥/០៧/២០១៤ នៅខេត្តកំពង់ចាម ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។
- លោក ហៀង ហឿន អនុការិយាល័យសេដ្ឋកិច្ចជនបទ បានចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីគម្រោងបង្កើតប្រាក់ចំណូល ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៤ នៅក្រចេះឧបត្ថម្ភដោយ PYD។
- លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយណែនាំ ស្តីពីកាអនុវត្តន៍កម្មវិធី (CLTS) ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០១៤ នៅខេត្តកំពង់ចាម ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។
- លោកប្រធានមន្ទីរ លឹម ជាវហាវ លោក ម៉ៅ សុខជា និងមន្ត្រីក្រោមឱវាទចំនួន ១២ រូប បានចូលរួមសិក្ខាសាលាស្តីពី ការផ្លាស់ប្តូរបទពិសោធន៍ការងារ ពង្រឹងសមត្ថភាពអភិវឌ្ឍន៍សហគមន៍ កាលពីថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៤ នៅ សណ្ឋាគារ ហ៊ា ប៊ុន្នី ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។

- លោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការបង្ការគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម និងវិធីសង្គ្រោះបន្ទាន់ កាលពីថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៤ នៅខេត្តកណ្តាល ឧបត្ថម្ភដោយអង្គភាពមីនកម្ពុជា។
- លោក លឹម ជាវហាវ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិ ស្តីពី សន្តិសុខស្បៀង និងអាហាររូបត្ថម្ភ កាលពីថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមការឧបត្ថម្ភដោយរាជរដ្ឋាភិបាលកម្ពុជា។
- លោក ធន សារី អនុប្រធានមន្ទីរបានចូលរួមសិក្ខាសាលាស្តីពី ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល កាលពីថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១៤ នៅសាលាខេត្ត ឧបត្ថម្ភដោយសាលាខេត្ត។
- លោក អ៊ុត អុល អនុប្រធានមន្ទីរបានចូលរួមសិក្ខាសាលាស្តីពី ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ចាប់ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៤ នៅសាលាខេត្ត ឧបត្ថម្ភដោយសាលាខេត្ត។
- លោក លឹម ជាវហាវ លោក ធន សារី លោក សុខ ស៊ីថា ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក លោក ម៉ៅ ឌឹម និងលោក ផេង ស៊ីណិត មន្ត្រីការិយាល័យរដ្ឋបាល និងបុគ្គលិក បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក ចាប់ពីថ្ងៃទី ២១ ដល់ថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៤ នៅខេត្តកំពង់ចាម ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។
- លោក លឹម ជាវហាវ និង លោក សុខ ស៊ីថា ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីលិខិតបទដ្ឋានគតិយុត្ត និងការគ្រប់គ្រងធនធានមនុស្ស និងការផ្តល់សេវាកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ នៅខេត្តក្រចេះ ឧបត្ថម្ភដោយសាលាខេត្ត ។
- លោក លឹម ជាវហាវ លោក ធន សារី លោក ឱក រ៉េត លោក តុញ យ៉ាវ និងលោក សេង ឡុងឌី បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធី Arc GIS 10 និងពង្រឹងការប្រើប្រាស់ GPS ចាប់ពីថ្ងៃទី០៣-០៥ ខែកញ្ញា ឆ្នាំ២០១៤ នៅខេត្តរតនគិរី ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។
- លោក មាន គឹមតេង អនុប្រធានការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការចងក្រងផែនការគ្រប់គ្រងព្រៃឈើ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤ នៅខេត្តក្រចេះ ឧបត្ថម្ភដោយរដ្ឋបាលព្រៃឈើ ។
- លោក លឹម ជាវហាវ និងលោក សន ធី ប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ បានចូលរួមសិក្ខាសាលាពីការបញ្ចូលផែនការថវិកា ឆ្នាំ ២០១៥ រវាងថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាសម្រាប់រាជធានីខេត្ត កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ នៅខេត្តព្រះសីហនុ ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ ។

- លោក ឈាង ស៊ីថា អនុប្រធានការិយាល័យបណ្តុះបណ្តាល និងលោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ ចាប់ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៤ នៅស្រុកស្នួល និងស្រុកព្រែកប្រសព្វ ឧបត្ថម្ភដោយសាលាស្រុកស្នួល និងសាលាស្រុកព្រែកប្រសព្វ ។
- លោក ធន សារី អនុប្រធានមន្ទីរ លោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ លោក សន ធី ប្រធានការិយាល័យ គណនេយ្យ -ហិរញ្ញវត្ថុ និង ធុន បូនិត (ស) មន្ត្រីការិយាគណនេយ្យ -ហិរញ្ញវត្ថុ បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹង សមត្ថភាពអនុវត្តថវិកាកម្មវិធី កាលពីថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៤ នៅខេត្តព្រះសីហនុ ក្រោមការឧបត្ថម្ភដោយ ក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការជាតិអភិវឌ្ឍន៍កុមារ កាលពីថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៤ នៅខេត្តរតនគីរី ក្រោមការឧបត្ថម្ភដោយ ក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោក សុខ ស៊ីថា ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក លោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ លោក ផេង ស៊ីណិត មន្ត្រីការិយាល័យរដ្ឋបាល និងបុគ្គលិក និងធុន បូនិត (ស្រី) មន្ត្រីការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងអនុវត្តការរៀបចំផែនការ និងគ្រប់គ្រងធនធានមនុស្ស ចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារ លីជី ក្រោមការឧបត្ថម្ភដោយសាលាខេត្តក្រចេះ ។
- លោក លឹម ជាវហាវ ប្រធានមន្ទីរ លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ លោក សោម ជួន អនុប្រធានការិយាល័យបណ្តុះបណ្តាល បានចូលរួមសិក្ខាសាលា បូកសរុបលទ្ធផលស្តីពីការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍន៍ធនធានមនុស្ស កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោក លឹម ជាវហាវ ប្រធានមន្ទីរ លោក មាន គឹមតេង អនុប្រធានការិយាល័យជនជាតិដើមភាគតិច បានចូលរួមសិក្ខាសាលាការផ្សព្វផ្សាយ ការអនុវត្តយន្តការអន្តរក្រសួង លើការពង្រឹងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារ រតនៈស៊ីធី ក្រោមការឧបត្ថម្ភដោយអង្គការ NGOs forum ។
- លោក លឹម ជាវហាវ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី លទ្ធផលផែនការការចុះសិក្សាផលប៉ះពាល់បរិស្ថានគម្រោងវិនិយោគ ដីសម្បទានក្រុមហ៊ុន អេសប៊ីខេ កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសាលប្រជុំសាលាខេត្ត ក្រោមការឧបត្ថម្ភដោយសាលាខេត្តក្រចេះ ។
- លោក លឹម ជាវហាវ លោក ធន សារី លោក អ៊ុត អុល លោក សន ធី បានចូលរួមសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវផែនការថវិកា សម្រាប់អនុវត្តអង្គភាពថវិកា ២០១៥ កាលពីថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៤ សណ្ឋាគារភ្នំពេញ ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ ។

- លោក លឹម ជាវហាវ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំ ស្តីពី ការរៀបចំគម្រោង កាលពីថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៤ នៅសាលប្រជុំសាលាខេត្ត ក្រោមការឧបត្ថម្ភដោយសាលាខេត្តក្រចេះ ។

4. <u>**ទិសដៅបន្ត**</u>

- បន្តជំរុញការងារគ្រប់គ្រងលិខិតទៅតាមគតិយុត្ត និងរៀបចំតម្លើងកាំប្រាក់ និងប្រាក់បំណាច់មុខងារជូនបុគ្គលិកមន្ត្រីរាជការដែលមានស្នាដៃ និងរៀបចំបញ្ជីវត្តមានជាប្រចាំ ពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់
- ត្រួតពិនិត្យសកម្មភាពនានា និងផែនការដែលបានលើកឡើងដើម្បីកែតម្រូវ និងធ្វើបច្ចុប្បន្នភាពផែនការប្រចាំឆ្នាំឲ្យកាន់តែមានភាពសុក្រឹត
- បន្តរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ជូនអង្គភាព និងសាលាខេត្តក្រចេះ
- បន្តរៀបចំធ្វើផែនការសកម្មភាពប្រចាំត្រីមាស ដាក់ជូនសាលាខេត្តក្រចេះ
- ត្រៀមចូលរួមប្រជុំ សិក្ខាសាលាតាមការអញ្ជើញរបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍នានា និងធ្វើសមាហរណកម្មផែនការឃុំ សង្កាត់
- ថែទាំផ្លូវលំជនបទជាលក្ខណៈខួប មានប្រវែង ៣៣.៨០ គ.ម ស្ថិតនៅឃុំសោប ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ ឃុំឃ្សឹម ស្រុកស្នួល
- ថែទាំផ្លូវលំជនបទជាលក្ខណៈប្រចាំ មានប្រវែង ២៨.២០ គ.ម ស្ថិតនៅឃុំចង្ក្រង់ ឃុំថ្មគ្រែ ឃុំគោលាប់ ឃុំដារ ស្រុកចិត្របុរី
- ការងារជួសជុលផ្លូវ ៦.៨០ គ.ម ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- ចុះយកទិន្នន័យផ្លូវលំជនបទក្នុងខេត្តក្រចេះបន្ថែម ដែលមន្ទីរពុំបានគ្រប់គ្រងពីមុនមក
- រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌផ្លូវលំជនបទក្នុងខេត្តក្រចេះ
- ស្រង់ទិន្នន័យអណ្តូងខូចនៅស្រុកចិត្របុរី ស្រុកសំបូរ និងស្នួល
- ផ្សព្វផ្សាយពីការប្រើប្រាស់ទឹក
- ជួសជុលអណ្តូងស្នប់ M3 ៩អណ្តូង អណ្តូងស្នប់អាហ្វ្រិដែល ២៨អណ្តូង អណ្តូងលូ ២១អណ្តូង និងផ្លាស់ប្តូរស្នប់តារា ០៥ អណ្តូង
- ជួសជុលអណ្តូងស្នប់ ៦៥ អណ្តូង (ថវិកាខេត្ត)
- ចុះពិនិត្យ និងតាមដាន (ថវិកាខេត្ត)
- បណ្តុះបណ្តាលដល់គ្រូបង្គោលក្រុមប្រឹក្សាឃុំស្តីពីការលើកកម្ពស់អនាម័យសុខភាពជនបទ
- បំផុស និងផ្សព្វផ្សាយប្រជាជន ឲ្យសាងសង់បង្គន់អនាម័យទាំង០៥ ស្រុក
- តាមដាន និងត្រួតពិនិត្យការសាងសង់បង្គន់អនាម័យទាំង ០៥ ស្រុក

- តាមដានសមាសភាពគ.អ.ភ ឡើងវិញ
- បណ្តុះបណ្តាលគ.អ.ភ ស្តីពីការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ
- បណ្តុះបណ្តាលប្រជាពលរដ្ឋ និងគ.អ.ភ ស្តីពីសន្តិសុខស្បៀង
- គម្រោងអភិវឌ្ឍន៍ភូមិចម្រុះ
- បណ្តុះបណ្តាលគ.អ.ភ ស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ
- បន្តបង្កើនសមត្ថភាពបណ្តុះបណ្តាលធនធានមនុស្សក្នុងអង្គភាព
- ផ្សព្វផ្សាយពីគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងស្រុកព្រែកប្រសព្វ និងស្រុកឆ្លូង
- រៀបចំបង្កើតសហគមន៍ជនជាតិភាគតិចគួយនៅឃុំបឹងចារ និងអូរគ្រៀង ស្រុកសំបូរ ដោយសហការជាមួយអង្គការដៃគូ
- បន្តសហការពង្រឹងសហគមន៍ផ្តល់ប្រាក់កម្ចីឃុំបុសលាវ ឃុំកោះច្រែក ឃុំព្រែកប្រសព្វ និងឃុំវឌ្ឍនៈ ។

**ប្រធានមន្ទីរ**